**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៤ អផណ.កប៩

# សេចក្តីថ្លែងហេតុ
# អំពី
# សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើវិសោធនកម្ម ពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន

ព្រះរាជាណាចក្រកម្ពុជាយើងបានផ្តល់សច្ចាប័នលើអនុសញ្ញាក្រុងវីយែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន និងពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូននៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១ និងបានផ្តល់សច្ចាប័នលើវិសោធនកម្មចំនួនបួន នៃពិធីសារម៉ុងរ៉េអាល់ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ រួមមាន វិសោធនកម្មក្រុងឡុងដុង វិសោធនកម្មក្រុងកូបេនហាហ្គេន វិសោធនកម្មក្រុងម៉ុងរ៉េអាល់ និងវិសោធនកម្មក្រុងប៉េកាំង។ ក្នុងនាមជាសមាជិក ប្រទេសកម្ពុជាមានកាតព្វកិច្ចអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញាក្រុងវីយែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន និងពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន សំដៅកាត់បន្ថយនិងលុបបំបាត់ការផលិតនិងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន។

វិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូនមានចំនួន៥មាត្រា ដែលមានខ្លឹមសារសង្ខេបសំខាន់ៗដូចតទៅ៖ មាត្រាI-វិសោធនកម្ម, មាត្រាII-ទំនាក់ទំនងនៃវិសោធនកម្មឆ្នាំ១៩៩៩, មាត្រាIII-ទំនាក់ទំនងរវាងអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនិងពិធីសារក្យូតូ, មាត្រាIV-ការចូលជាធរមាន, មាត្រាV-ការដាក់ពាក្យបណ្តោះអាសន្ន។

ដើម្បីឱ្យការអនុវត្តអនុសញ្ញាក្រុងវីយែន និងពិធីសារម៉ុងរ៉េអាល់ឱ្យមានប្រសិទ្ធភាពក្នុងការកាត់បន្ថយ និងឈានទៅរកការលុបបំបាត់នូវការផលិតនិងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុហាយដ្រូភ្លុយអរ៉ូកាបូន(HFCs) ដែលជាសារធាតុបង្កឱ្យមានការកើនកម្តៅភពផែនដីខ្ពស់ ដូចនេះប្រតិភូមកពីប្រទេសចំនួន១៩៧ រួមទាំងប្រទេសកម្ពុជា តំណាងកម្មវិធីបរិស្ថានសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានអនុម័តលើវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន សំដៅកាត់បន្ថយការផលិតនិងការប្រើប្រាស់សារធាតុហាយដ្រូភ្លុយអរ៉ូកាបូន នៅកិច្ចប្រជុំភាគីលើកទី២៨ នាឆ្នាំ២០១៦ នៅទីក្រុងគីហ្គាលីនៃប្រទេសរវ៉ាន់ដា។ បន្ទាប់ពីវិសោធនកម្មទាំង៤នៃពិធីសារម៉ុងរ៉េអាល់ត្រូវបានផ្តល់សច្ចាប័នជាសកល ការអនុវត្តវិសោធនកម្មទាំងនេះបានរួមចំណែកក្នុងការកាត់បន្ថយការផលិតនិងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូនរហូតដល់៩៨ភាគរយនៅឆ្នាំ២០១៦។

វិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន(ក្រុងគីហ្គាលី) បានចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ដោយបានដាក់ចេញនូវវិធានការក្នុងការត្រួតពិនិត្យចំពោះការផលិត ការប្រើប្រាស់សារធាតុហាយដ្រូភ្លុយអរ៉ូកាបូន ធ្វើការរឹតបន្តឹងការផលិត ការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្ម

សារធាតុហាយដ្រូក្លរូយអរ៉ូកាបូនជាមួយប្រទេសមិនមែនជាសមាជិកនៃវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន(ក្រុងគីហ្គាលី)។ ដូចនេះ ប្រសិនបើប្រទេសកម្ពុជាមិនផ្ដល់សច្ចាប័នទេ នោះយើងនឹងមិនអាចនាំចូលសារធាតុទាំងនេះបានឡើយ។

យោងទៅលើការសិក្សាឯកសារនិងបទពិសោធរបស់យើងនិងពីប្រទេសនានានៅក្នុងតំបន់លើការអនុវត្តអនុសញ្ញានិងពិធីសារនេះ ដោយប្រៀបធៀបស្ថានភាពជាក់ស្ដែងនៅកម្ពុជា ការផ្ដល់សច្ចាប័នលើវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន(ក្រុងគីហ្គាលី)មានសារៈប្រយោជន៍ដូចខាងក្រោម៖

ក. ក្នុងនាមជាសមាជិកនៃវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន(ក្រុងគីហ្គាលី) ប្រទេសកម្ពុជាពុំត្រូវបង់ថវិកាប្រចាំឆ្នាំឡើយ

ខ. ក្នុងនាមជាសមាជិកនៃអនុសញ្ញានិងពិធីសារនិងវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន(ក្រុងគីហ្គាលី) ប្រទេសកម្ពុជាមានកាតព្វកិច្ចចូលរួមជាមួយសហគមន៍អន្តរជាតិក្នុងការទប់ស្កាត់ការបំផ្លាញស្រទាប់អូហ្សូន និងការកើនកម្ដៅភពផែនដីដែលបង្កដោយសារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុហាយដ្រូក្លរូយអរ៉ូកាបូន តាមរយៈការកាត់បន្ថយការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូននិងសារធាតុហាយដ្រូក្លរូយអរ៉ូកាបូន។ ប្រទេសជាសមាជិកត្រូវរៀបចំប្រព័ន្ធស្នើសុំលិខិតអនុញ្ញាតកូតាក្នុងការផលិត ការនាំចេញនិងការនាំចូល ការកាត់បន្ថយការប្រើប្រាស់សារធាតុហាយដ្រូក្លរូយអរ៉ូកាបូននិងឧបករណ៍ដែលប្រើប្រាស់សារធាតុនេះ ជាពិសេសទូរទឹកកកនិងបរិក្ខារត្រជាក់មួយចំនួនដែលភាគច្រើនជាបរិក្ខារចាស់ៗ ជាធម្មតាប្រទេសនៅក្នុងពិភពលោកកំពុងរកកន្លែងបោះចោលហើយបរិក្ខារទាំងនេះនឹងត្រូវប្រើប្រាស់លែងកើតបន្ទាប់ពីសារធាតុទាំងនេះត្រូវបានលុបបំបាត់ទាំងស្រុង។

គ. ទទួលផលចំណេញផ្នែកនយោបាយ

- បង្ហាញពីឆន្ទៈរបស់ប្រទេសកម្ពុជាក្នុងការរួមចំណែកដោះស្រាយបញ្ហាការពារស្រទាប់អូហ្សូន
- លើកកម្ពស់កិត្យានុភាពជាតិតាមរយៈការចូលរួមកិច្ចប្រជុំពិភាក្សាដោះស្រាយបញ្ហាកាត់បន្ថយនិងឈានទៅលុបបំបាត់សារធាតុបំផ្លាញស្រទាប់អូហ្សូន។

ឃ. ទទួលផលចំណេញផ្នែកបរិស្ថាន

- ក្នុងនាមជាសមាជិកនៃវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន(ក្រុងគីហ្គាលី) ប្រទេសកម្ពុជានឹងចូលរួមចំណែកទប់ស្កាត់និងកាត់បន្ថយការកើនកម្ដៅភពផែនដីដែលបង្កឱ្យខូចខាតបរិស្ថានធម្មជាតិ ជីវៈចម្រុះ និងប៉ះពាល់ដល់សុខភាពសាធារណៈ
- ចូលរួមចំណែកជាមួយសហគមន៍អន្តរជាតិក្នុងការទប់ស្កាត់ការកើនកម្ដៅភពផែនដី
- ទទួលបានការគាំទ្រលើជំនួយបច្ចេកទេសក្នុងការបណ្ដុះបណ្ដាល ការផ្ដល់នូវបច្ចេកវិទ្យាថ្មីៗ ការទទួលបានព័ត៌មាននិងជំនួយជាថវិកាសម្រាប់អនុវត្តគម្រោងទាក់ទងនឹងការអនុវត្តវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន(ក្រុងគីហ្គាលី) នេះដូចជាការកែច្នៃ ការត្រួតពិនិត្យការនាំចូលបរិក្ខារដែលប្រើប្រាស់សារធាតុហាយដ្រូក្លរូយអរ៉ូកាបូនប្រកបដោយសុវត្ថិភាព។ មកដល់បច្ចុប្បន្ននេះ យើងទទួលបានជំនួយក្នុងការរៀបចំនិងអនុវត្តកម្មវិធីជាតិស្ដីពីការគ្រប់គ្រងសារធាតុធ្វើឱ្យត្រជាក់ ដើម្បីកាត់បន្ថយនិងលុបបំបាត់សារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលក្នុងនោះមានការអនុវត្តគម្រោងបណ្ដុះបណ្ដាលមន្ត្រីអនុវត្តច្បាប់ រួមមានមន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីគយ និងមន្ត្រីកាំកុងត្រូល គម្រោងបណ្ដុះបណ្ដាលបច្ចេកទេស គម្រោងលើកទឹកចិត្តលើការផ្លាស់ប្ដូរប្រព័ន្ធម៉ាស៊ីនត្រជាក់ និងគម្រោងពង្រឹងសមត្ថភាពស្ថាប័នផងដែរ។

ង. ផលចំណេញផ្នែកសេដ្ឋកិច្ច

- ដោយសារព្រះរាជាណាចក្រកម្ពុជាយើងមិនមែនជាប្រទេសអ្នកផលិតឬជាប្រទេសនាំចេញឧបករណ៍និងសារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ ដូចនេះការផ្ដល់សច្ចាប័ននេះមិនបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ព្រះរាជាណាចក្រកម្ពុជាយើងទេ
- មានសិទ្ធិក្នុងការនាំចូលសារធាតុហាយដ្រូភ្លុយអរ៉ូកាបូនសម្រាប់បំពេញសេចក្ដីត្រូវការក្នុងប្រទេស
- ទប់ស្កាត់បានទាន់ពេលវេលានូវការនាំចូលឧបករណ៍ដែលប្រើប្រាស់សារធាតុហាយដ្រូភ្លុយអរ៉ូកាបូនដែលបរិក្ខារទាំងនេះនឹងប្រើការលែងកើតបន្ទាប់មកនឹងក្លាយទៅជាសំណល់ ហើយត្រូវរកកន្លែងបោះចោលក្រោយពីសារធាតុហាយដ្រូភ្លុយអរ៉ូកាបូនត្រូវបានលុបបំបាត់
- ទទួលបានថវិកាក្នុងការអនុវត្តគម្រោងលើកទឹកចិត្តក្នុងការផ្លាស់ប្ដូរប្រព័ន្ធម៉ាស៊ីនត្រជាក់រថយន្តការប្រើប្រាស់ឡើងវិញ ការកែច្នៃសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ដែលថវិកាទាំងនេះទទួលបានពីថវិកាពហុភាគីនិងទ្វេភាគី
- ទទួលបានថវិកាក្នុងការរៀបចំប្រព័ន្ធផ្ដល់អនុញ្ញាតតាមប្រព័ន្ធអេឡិកត្រូនិកក្នុងការត្រួតពិនិត្យការនាំចេញនិងការនាំចូលសារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ដែលអាចទប់ស្កាត់ចរាចរទំនិញខុសច្បាប់ប្រកបដោយប្រសិទ្ធភាព
- ទទួលបានគម្រោងវិនិយោគដើម្បីកែសម្រួលខ្សែច្រវ៉ាក់ផលិតកម្មពីការប្រើប្រាស់សារធាតុហាយដ្រូភ្លុយអរ៉ូកាបូនទៅប្រើប្រាស់សារធាតុមិនបំផ្លាញស្រទាប់អូហ្សូនវិញ ដែលថវិកាទាំងនេះនឹងទទួលបានពីថវិកាពហុភាគីឬទ្វេភាគី ហើយតិចឬច្រើនទៅតាមទំហំមូលដ្ឋានផលិតកម្មដែលយើងមាន។

សរុបសេចក្ដីមក ការផ្ដល់សច្ចាប័នលើវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន(ក្រុងគីហ្គាលី)ពុំនាំមកនូវផលវិបាកជាអវិជ្ជមានណាមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់កម្ពុជាឡើយ ផ្ទុយទៅវិញយើងបានចូលរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល គោលនយោបាយកាត់បន្ថយភាពក្រីក្រ លើកកម្ពស់កិច្ចគាំពារបរិស្ថាន ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនិងអភិរក្សធនធានធម្មជាតិសំដៅឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាព។

សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ដើម្បីបញ្ជូនទៅសុំការពិនិត្យនិងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ដែលរួមមាន២មាត្រា។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យនិងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ដោយក្ដីអនុគ្រោះ។

ថ្ងៃ សុក្រ ១០ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**